# ការទទួលខុសត្រូវជំនួសអ្នកដៃ (Vicarious Liability)

១. ច្បាប់ព្រហ្មទណ្ឌ ចែងអំពីការទទួលខុសត្រូវរបស់បុគ្គល ឬក្រុមហ៊ុន (នីតិបុគ្គល) ចំពោះអំពើល្មើសច្បាប់។ ការទទួលខុសត្រូវអំពើរបស់ខ្លួន មិនជាបញ្ហាច្បាប់ចោទឡើងទេ។ អ្វីជាបញ្ហា គឺការទទួលខុសត្រូវរបស់បុគ្គលម្នាក់ចំពោះអំពើល្មើសរបស់អ្នកដទៃក្នុងការទទួលខុសត្រូវជំនួស (vicarious liability: VL)។

២. VL ខុសពីទម្រង់ទទួលខុសត្រូវតឹងរឹង (strict liability: SL) ដែលទម្រង់ខាងក្រោយនេះនឹងនាំឲ្យបុគ្គលទទួលខុសត្រូវ ដោយគ្រាន់តែបានបំពេញ ធាតុផ្សំសម្ភារៈនៃបទល្មើស។ ក្នុងទំនាក់ទំនងរវាង ក្រុមហ៊ុន និងមន្ត្រី ក្នុងបរិបទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ទម្រង់ទាំងពីរ អាចត្រូវបានប្រើរួមគ្នា។ មន្ត្រី ទទួលខុសត្រូវក្នុងទម្រង់ SL រីឯក្រុមហ៊ុនទទួលខុសត្រូវជំនួសមន្ត្រី តាម VL។ វាអាស្រ័យទៅតាមប្រភេទបទល្មើស ឬសកម្មភាពល្មើស។ ក្នុងករណីខ្លះ ក្រុមហ៊ុនទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនផ្ទាល់ (ទង្វើរបស់ក្រុមប្រឹក្សាភិបាល ជាទង្វើផ្ទាល់របស់ក្រុមហ៊ុន) និងចំពោះអំពើនៃមន្ត្រី។ វាមិនមានអ្វីចំលែកទេ ដោយសារថា ទោះបីជាក្រុមហ៊ុន ជាអង្គភាពអរូបិយ តែមានរចនាសម្ព័ន្ធ ដោយឡែកពីមន្ត្រីរបស់ខ្លួន។

៣. ក្រៅពីដាក់ការរទទួលខុសត្រូវរបស់ក្រុមហ៊ុន (legal entity) ចំពោះអំពើរបស់មន្ត្រី (official) http://www.measboralaws.com/detail/13 VL ត្រូវបានប្រើផងដែរសម្រាប់មាតាបិតា ទទួលខុសត្រូវចំពោះទង្វើរបស់កូនដែលជាអនីតិជនhttp://www.measboralaws.com/detail/1045 ឬការទទួលខុសត្រូវរបស់និយោជក (employer) ចំពោះទង្វើខុសច្បាប់របស់និយោជិក (employee) http://www.measboralaws.com/detail/1044។ ករណីចុងក្រោយនេះ ដូចជាការទទួលខុសត្រូវរបស់ម្ចាស់ហាងស្រាចំពោះបុគ្គលិក ដែលលក់ស្រាដល់អតិថិជន ទោះបីក្រោយមកទើបដឹងថា ជាអនីតិជន ហើយទោះបីជាម្ចាស់ហាងមិនបានដឹង ឬគ្មានចេតនាលក់ឲ្យអនីតិជនសោះ។ ច្បាប់នៃប្រទេសកំមុនឡ ដូចជាសហរដ្ឋអាមេរិក មានចែងនូវបទល្មើសមនុស្សឃាតដោយក្រុមហ៊ុន (corporate manslaughter) ដែល ដាក់ការទទួលខុសត្រូវលើក្រុមហ៊ុននូវអំពីដែលធ្វើឲ្យមនុស្សស្លាប់។

៤. VL មិនមែនជាការទទួលខុសត្រូវដាច់ខាតទេ។ ខុសពីការទទួលខុសត្រូវព្រហ្មទណ្ឌធម្មតា និយោជក ឬនីតិបុគ្គល ដែលជាចុងចម្លើយ មានបន្ទុកដាក់ភស្តុតាង ដើម្បីរួចផុតពីការទទួលខុសត្រូវ ដោយបង្ហាញថា ខ្លួន ឬក្រុមហ៊ុនមិនបានប្រព្រឹត្តខុស (affirmative defence) ដូចជា៖ ១. ទោះបីធ្វើឡើងដើម្បីប្រយោជន៍ក្រុមហ៊ុនមែន ក៏ប៉ុន្តែទង្វើរបស់មន្ត្រីផ្ទុយនឹងគោលនយោបាយរបស់ក្រុមហ៊ុននិង

មិនមែនធ្វើក្នុងវិសាលភាពការងាររបស់មន្ត្រីពាក់ព័ន្ធនោះទេ (the responsible of a superior/resp-ondeat superior test) ឬ ២. មិនបានបញ្ជា អនុញ្ញាត ឬ យោគយល់ដោយក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន។

៥. ការអនុវត្ត (ករណីលក់ស្រា) ធ្វើឲ្យមានការរិះគន់ជាខ្លាំង ដោយសារការដាក់ការទទួលខុសត្រូវយ៉ាងនេះ ប៉ះដល់គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌដ៏ចង្អៀត (អ្នកប្រព្រឹត្តទទួលខុសត្រូវអំពើប្រព្រឹត្តរបស់ខ្លួន) ហើយក្នុងករណីនេះ ម្ចាស់ហាង មិនមានចេតនាអ្វីសោះ។ ទោះបី ទណ្ឌកម្មជាពិន័យក្តី វាក៏អាចនាំឲ្យក្រុមហ៊ុនតម្លើងថ្លៃសេវា ដើម្បីយកមកដោះស្រាយប្រាក់ចំណាយលើពិន័យ ឬ ទោសធ្ងន់ធ្ងរ (ការបិទក្រុមហ៊ុន) ដែលនឹងប៉ះពាល់ដល់បុគ្គលិកដទៃដែលគ្មានកំហុស (innocent staff)។ ការដាក់ទទួលខុសត្រូវរបៀបនេះ វាដូចជា criminal vicarious liability ដែលអនុវត្តនៅប្រទេសចិនសម័យបុរាណ (កូនអាចត្រូវបានប្រហារជីវិតជំនួសឪពុកដែលជាឃាតករ)។

៦. អ្នកគាំទ្រ ឆ្លើយតបថា ទង្វើខ្លះ បំពានបទល្មើសសុខុមាលភាពសាធារណៈ (public welfare offenses) ផលបង្កអាចធំធេង មិនអាចជួសជុលឲ្យដូចភាពដើមវិញ (irreparable) ដែលតម្រូវឲ្យមានការបង្ការប្រសើរជាងការព្យាបាល។ ការខូចខាត អាចបង្កឡើងដោយបុគ្គលជាច្រើន ដែលពេលខ្លះមានការលំបាកក្នុងការរកអ្នកទទួលខុសត្រូវពិតប្រាកដ។ ការដាក់ការទទួលខុសត្រូវ ធ្វើឲ្យនិយោជក ឬ ក្រុមហ៊ុន នាំឲ្យមានការប្រយ័ត្នប្រយែងក្នុងប្រតិបត្តិការជំនួញរបស់ខ្លួន ហើយការជ្រើសរើសបុគ្គលិក ទាមទារនូវភាពហ្មត់ចត់ ដោយសារថា ទង្វើរបស់និយោជិក អាចនាំឲ្យនិយោជកទទួលខុសត្រូវ។ ការដាក់បន្ទុកនេះ ជួយបង្កាកុំឲ្យនិយោជក ដោះសាររួចផុតពីការទទួលខុសត្រូវ ដោយអះអាងថា វាមិនមែនជាអំពើរបស់ខ្លួន ឬអំពើរបស់ក្រុមហ៊ុន។

៧. ជាការពិត ទម្រង់នៃការទទួលខុសត្រូវនេះ នៅតែមានភាពចម្រូងចម្រាស់។ អាស្រ័យហេតុនេះ ដោយសារ វាស្រដៀងនឹងទម្រង់ទទួលខុសត្រូវសមគំនិត ( accomplice) (ដូចជា ការជួយ) ប្រទេសខ្លះបានយកទម្រង់នេះមកប្រើជំនួស VL ឬប្រសិនបើប្រើប្រាស់ ទោសទណ្ឌនឹងត្រឹមតែជាពិន័យ ដែលអាចច្រើនឬតិចទៅតាមទំហំនៃការខូចខាត។

**កំណត់សំគាល់៖** ពាក់ព័ន្ធនឹងទម្រង់ទទួលខុសត្រូវនេះ ច្បាប់កម្ពុជា មានចែងអំពីការទទួលខុសត្រូវរបស់នីតិបុគ្គលក្នុងមាត្រា ៤២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩៖ *នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្ម*

*ទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ* http://www.measboralaws.com/detail/950 ព្រមទាំងការទទួលខុស ត្រូវរបស់មាតាបិតា និង របស់និយោជក ក្នុងមាត្រា ៧៤៦ ៧៤៧ ៧៤៨ និង ៧៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ (ស្តីពី អំពើអនីត្យានុកូលភាព) http://www.measboralaws.com/detail/723។

**ឯកសារយោង៖** **1**. Richard Owen, Essential Tort Law, 200, pp. 57-71; **2**. Alan C. Michaels, Vicarious Liability, in Joshua Dressler, Encyclopedia of Crime and Justice, 2002, pp. 1622-1625 and **3**. William R. Buckley, Torts and Personal Injury Law, 1993, pp. 239-260; Matthew Lippman, Contemporary Criminal Law, 2010, pp.166-177.